**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការទទួលស្គាល់សាកលវិទ្យាល័យ ស៊ីធី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្ដីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំរបស់ លោក ហ៊ិន ហរ៉ែណ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៥
- បានឃើញលិខិតលេខ ២៣១៩ អយក.ឧស ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥ របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១** : ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា **សាកលវិទ្យាល័យ ស៊ីធី** ( City University ) ហៅកាត់ជាភាសាខ្មែរ " ស.ស " និងហៅកាត់ជាភាសាអង់គ្លេស " C.U "។ សាកលវិទ្យាល័យ នេះ មានទីតាំងស្ថិតនៅ អគារលេខ ១១៩ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**មាត្រា ២** : សាកលវិទ្យាល័យ ស៊ីធី មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣** : សាកលវិទ្យាល័យ ស៊ីធី ធ្វើការបណ្តុះបណ្តាលកម្រិត :

-ថ្នាក់បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ឆ្នាំ ត្រូវនឹង ៧០ក្រេឌីត ជាមធ្យម

-ថ្នាក់បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ឆ្នាំ ត្រូវនឹង ១៤០ក្រេឌីត ជាមធ្យម

-ថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ សិក្សារយៈពេល ២ឆ្នាំ ត្រូវនឹង ៥៤ក្រេឌីត ជាមធ្យម

-ថ្នាក់បណ្ឌិត សិក្សាស្រាវជ្រាវរយៈពេល ៣ឆ្នាំ

សាកលវិទ្យាល័យនេះ ត្រូវរៀបចំកម្មវិធីសិក្សាលំអិត ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤** : ក្នុងដំណើរការចាប់ផ្តើមនេះ សាកលវិទ្យាល័យ ស៊ីធី មានមហាវិទ្យាល័យ ចំនួន ០៥ គឺ :

១-មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា : ឯកទេសអក្សរសាស្ត្រអង់គ្លេស

២-មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ : ឯកទេសវិទ្យាសាស្ត្រកុំព្យូទ័រ អគ្គិសនី និងអេឡិចត្រូនិច

៣-មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម : ឯកទេសសេដ្ឋកិច្ច និងវិទ្យាសាស្ត្រនយោបាយ

៤-មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍ : ឯកទេសគ្រប់គ្រង គណនេយ្យ ទីផ្សារ ហិរញ្ញវត្ថុ គ្រប់គ្រងទេសចរណ៍ និងគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិ

៥-មហាវិទ្យាល័យនីតិសាស្ត្រ : ឯកទេសនីតិសាស្ត្រ

ទៅអនាគត សាកលវិទ្យាល័យ ស៊ីធី អាចពង្រីក ឬប្តូរទីតាំង បើកមហាវិទ្យាល័យ សាខា ឯកទេស និងប្រភេទបណ្តុះបណ្តាលដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥** : សាកលវិទ្យាល័យ ស៊ីធី ដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយ ដែលមានភារកិច្ចអនុម័តលើកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធ។

**មាត្រា ៦** : សាកលវិទ្យាល័យ ស៊ីធី ត្រូវអនុវត្តតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាល ដែលបានកំណត់លើសកម្មភាព ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាល។

**មាត្រា ៧** : តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែង របស់សាកលវិទ្យាល័យ ស៊ីធី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យ និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៨ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យ ស៊ីធី មានភារកិច្ចទទួលខុសត្រូវ ចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ធានាឱ្យបាននូវសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ហើយនិងធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៩ :** និស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យ ស៊ីធី និងទទួលបានជោគជ័យ ក្នុងការប្រឡងបញ្ចប់ការសិក្សានោះ ត្រូវទទួលបានសញ្ញាប័ត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យ ស៊ីធី ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី សាកលវិទ្យាល័យ បំពេញ និងអនុវត្តបានតាមគោលការណ៍កំណត់របស់ ក្រសួងអប់រំ យុវជន និង កីឡា។

**មាត្រា ១០ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យ ស៊ីធី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ